# កិច្ចសំភាសន៍របស់លោកពូឈ្មោះ វ៉ា រតនៈ

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជារី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ វ៉ា រតនៈ

កៈ ចាស! ជាដំបូងសូមជំរាបសួរលោកពូ!

ខៈ បាទ! ជំរាបសួរ!

កៈ ចាស! លោកពូថ្ងៃនេះខ្ញុំមានឳកាសមែនទែនដែលបានមកសំភាសន៍លោកពូផ្ទាល់ ហើយអឺ....ថ្ងៃនេះជាថ្ងៃទី០៤ ខែ០៧ ឆ្នាំ២០១៨ ហើយនាងខ្ញុំឈ្មោះ ហេង សុជារី ខ្ញុំជាអ្នកសំភាសន៍នៅក្នុងគំរោងរបស់សាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិច ហើយគំរោងសាលាមួយនេះគឺជាគំរោងរបស់ខាងសាលានៅខាងសហរដ្ឋអាមេរិចដែលគេធ្វើការចងក្រងសំលេងរបស់ប្រជាជនកម្ពុជាអំពីពង្សប្រវត្តិរបស់គាត់អំពីបទពីសោធន៍របស់គាត់តាំងពីមុនរហូតដល់ឥឡូវនិងដើម្បីជួយរក្សារវាទុកដើម្បីអោយកូនចៅជំនាន់ក្រោយទៀតពួកគេបានស្គាល់ជាពិសេសកូនចៅរបស់លោកពូផ្ទាល់តែម្តង
អញ្ចឹងថ្ងៃនេះខ្ញុំមានឳកាសអឺ....ដើម្បីមកធ្វើការសំភាសន៍លោកពូអញ្ចឹង
តើលោកពូអាចអនុញ្ញាតដើម្បីអោយខ្ញុំធ្វើការសំភាសន៍លោកពូដែរឬទេ?
(មានសំលេងរំខានពីខាងក្រៅ)

ខៈ បាទ! អត់អីទេ!

កៈ ចាស! អរគុណលោកពូ អញ្ចឹងមុនដំបូងនៃការសំភាសន៍ខ្ញុំសុំសួរឈ្មោះលោកពូសិន តើលោកពូមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំឈ្មោះៗអឺ....ឈ្មោះ រតនៈ !

កៈ ឈ្មោះលោកពូ រតនៈ ហើយឈ្មោះនិងត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណដែរឬទេលោកពូ?

ខៈ ឈ្មោះនិងត្រូវជាមួយនិងអត្តសញ្ញាណប័ណ្ណ!

កៈ ឈ្មោះរបស់លោកពូត្រូវទាំងនាមត្រកូលតែម្តងន៎លោកពូន៎!

ខៈ នាមត្រកូលរបស់ខ្ញុំឈ្មោះ វ៉ា រតនៈ !

កៈ អ៎....ហើយចុះឈ្មោះនិងអ្នកណាជាអ្នកដាក់អោយលោកពូដែរ?

ខ៖ ឈ្មោះរបស់ខ្ញុំគឺម្តាយរបស់ខ្ញុំគាត់ជាអ្នកដាក់អោយ!

ក៖
គាត់មានបានប្រាប់លោកពូទេថាឈ្មោះនិងមានអត្ថន័យអ្វីដែរបានជាគាត់ដាក់ឈ្មោះនិងអោយលោកពូអញ្ចឹង?

ខ៖ ព្រោះឈ្មោះមួយនិងជាត្រកូលរបស់លោកឪពុក ឈ្មោះត្រកូលរបស់ឪពុកខ្ញុំណាស់!

ក៖ អូ....ចាស ហើយលោកពូមានឈ្មោះហៅក្រៅដែរឬទេ?

ខ៖ មាន....មានតើ ឈ្មោះហៅក្រៅរបស់ខ្ញុំមានឈ្មោះ ស៊ី និងឈ្មោះហៅក្រៅ!

ក៖ អូ....អ្នកណាគេជាអ្នកដាក់អោយលោកពូដែរឈ្មោះហៅក្រៅនិង?

ខ៖ ឈ្មោះ ស៊ី បើនិយាយទៅឈ្មោះនិងខ្ញុំដាក់ខ្លួនឯង ដាក់ឈ្មោះនិងដោយខ្លួនឯង!

ក៖ អ៎....លោកពូស្រលាញ់ឈ្មោះនិងហ៎?

ខ៖ ស្រលាញ់ឈ្មោះ ស៊ី និងពីព្រោះមានមិត្តភក្តិឈ្មោះ ស៊ី ដែលតែដល់ពេលបែកមិត្តភក្តិនិងទៅក៏ដាក់ក៏ដាក់ឈ្មោះមិត្តភក្តិនិងតែម្តងទៅ!

ក៖ អូ....ល្អមែនទែនអស្ចារ្យមែនទែន ហើយមិត្តភក្តិរបស់លោកពូនិងប្រុសឬមួយក៏ស្រីលោកពូ?

ខ៖ មិត្តភក្តិនិងប្រុស!

ក៖ ប្រុសទេហ៎ ហើយកាលនិងគាត់ជាមិត្តភក្តិវិទ្យាល័យឬក៏ជាមិត្តភក្តិជាអ្នកជិតខាងគ្នាអញ្ចឹងលោកពូ?

ខ៖ អូ....ជាមិត្តភក្តិស្គាល់គ្នាជាអ្នកជិតខាង (មានសំលេងរំខាន)!

ក៖ លោកពូស្គាល់គ្នាតាំងពីតូចៗមកតែម្តងលោកពូ!

ខ៖ និយាយទៅជាមិត្តភក្តិស្គាល់គ្នាតាំងពីក្មេងៗមក!

ក៖
តែឥឡូវនិងអឺ....គាត់យ៉ាងមិចហើយលោកពូគាត់នៅតែៗទាក់ទងជាមួយលោកពូដដែលឬក៏បែកគ្នាទៅឆ្ងាយ?

ខ៖ និយាយទៅអត់ដែរបានជួបគ្នាទេគ្រាន់តែទាក់ទងតាម Facebook នៅតែស្គាល់គ្នា!

ក៖ អូ....ដឹងត្រឹមតែថាគាត់នៅសុខសប្បាយទេឥឡូវនិង (សើច)!

ខ៖ និងហើយៗ!

ក៖ ចាស! ហើយលោកពូមានឪពុក ហើយឪពុករបស់លោកពូគាត់មានឈ្មោះអ្វីដែរ?

ខ៖ ឪពុកម្ដាយរបស់ខ្ញុំហ៎អើយ...ម្ដាយមានឈ្មោះ ឆាយ សុវណ្ណារី ឪពុករបស់ខ្ញុំឈ្មោះ វ៉ា ផល្លា ប៉ុន្ដែឪពុកនិងជាឪពុកក្រោយ បើឪពុកបង្កើតរបស់ខ្ញុំគាត់បានស្លាប់បាត់ហើយនិងគាត់ស្លាប់តាំងពីខ្ញុំនៅតូចៗឯណោះ!

ក៖ ឪពុករបស់លោកពូគាត់មានបញ្ហាជំងឺចាស់ជរាឫយ៉ាងណាដែរលោកពូ?

ខ៖ និយាយទៅដូចថានិងហើយគាត់មានជំងឺរាំរៃស្លាប់មួយចំហៀងខ្លួនកើតជំងឺមហារីកគាត់ស្លាប់បាត់ទៅ!

ក៖ ចាស! ចុះលោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ មានអឺ....បងប្អូនប្រុសពីរនាក់ស្រីបីនាក់សរុបទាំងអស់ប្រាំនាក់ ហើយកូនឪពុកក្រោយទៀតបីនាក់ ទាំងអស់ប្រាំបីនាក់!

ក៖ អូ....ចាស ហើយទៅលោកពូអឺ....តើបងប្អូនរបស់លោកពូនិមួយៗគាត់មានឈ្មោះអ្វីខ្លះទៅលោកពូ?

ខ៖ ឈ្មោះអឺ....ប្រាប់ទាំងឈ្មោះ អញ្ចឹងត្រូវការឈ្មោះបងប្អូនរបស់ខ្ញុំទៀតហ៎?

ក៖ ចាស! លោកពូគឺដើម្បីចងក្រងវាទុកពីព្រោះវាគឺជាពង្សប្រវត្តិរបស់លោកពូផ្ទាល់ អញ្ចឹងនៅពេលកូនចៅរបស់លោកពូបានស្ដាប់ នេះខ្ញុំអឺ....លោកប៉ារបស់ខ្ញុំមានបងប្អូនប៉ុននេះនាក់ ហើយពួកគាត់ម្នាក់ៗមានឈ្មោះអញ្ចែកៗនិងហើយ!

ខ៖ ប៉ុន្ដែអត់មានប៉ះពាល់ដល់បងប្អូនរបស់ខ្ញុំណាហី? (មានសំលេងរំខានពីខាងក្រៅ)

ក៖ អត់មានប៉ះពាល់អ្វីទេពីព្រោះគ្រាន់តែអឺ....យើងធ្វើការ Record ទុកដើម្បីអឺ....អោយជាពត័មានរបស់លោកពូទេតែបើលោកពូអាចប្រាប់ក៏បានមិនប្រាប់ក៏បានដែរ!

ខ៖ អញ្ចឹងទេហ៎!

ក៖ ចាស! វាអត់មានអីត្រូវប៉ះពាល់គាត់ទេពីព្រោះយើងអត់មាននិយាយអីដែលប៉ះពាល់ដល់គាត់ផង!

ខ៖ បងប្អូនរបស់ខ្ញុំទាំងប្រាំបីនាក់មើលមានឈ្មោះ បងគេបង្អស់ឈ្មោះ សម រតនា ប៉ុន្តែបន្ទាប់មកនិងបងស្រីអឺ....បន្ទាប់មកខ្ញុំនិង ឈ្មោះ វ៉ា រតនៈ និងបន្ទាប់មកឈ្មោះ វ៉ា សុជារី បន្ទាប់មក វ៉ា សត្យា ហើឈ្មោះមួយទៀតគ្រាន់តែថាប្អូនស្រីមួយទៀតដូចជាអត់បានដាក់ត្រកូលឪពុកនិងទេគាត់ដាក់ត្រកូលផ្សេងទេ មិនដឹងត្រកូលអីទេនៀកពីព្រោះបែកផ្ញើរគេតាំងពីតូចមកនៅជាមួយឪពុកចិញ្ចឹមតាំងពីតូច!

ក៖ ចាស!

ខ៖ ពីព្រោះបងប្អូនមិនសូវបានរស់នៅជុំគ្នាទេច្រើនតែយកទៅផ្ញើរគេពីព្រោះអីយើងកាលនិងឪពុកម្ដាយក្រ!

ក៖ ចាស! លោកពូអញ្ចឹងសរុបមកបងប្អូនរបស់លោកពូមានប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនរបស់ខ្ញុំទាំងមុនហើយនិងក្រោយទាំងអស់ប្រាំបីនាក់!

ក៖ ទាំងបងប្អូនមុននិងក្រោយអឺ....បងប្អូនបង្កើតរបស់លោកពូ ឪពុកក្រោយនិងតើលោកពូមានបងប្អូនប៉ុន្មននាក់?

ខ៖ មានបងប្អូនបីនាក់!

ក៖ មានតែបងប្អូនបីនាក់ទេហ៎លោកពូ? បងប្អូនបង្កើតឪពុកជាមួយគ្នាហាសមានបីនាក់?

ខ៖ អឺ....ឪពុកបង្កើតរួមគ្នាមានប្រាំនាក់ ហើយឪពុកក្រោយនិងមានបីនាក់កើតពោះម្ដាយតែមួយ!

ក៖ ចាស! ចាស! អញ្ចឹងបងប្អូនបង្កើតទាំងអស់និងតើមានស្រីប៉ុន្មាននាក់ហើយប្រុសប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនបង្កើតទាំងអស់និងមានស្រីបីនាក់ហើយប្រុសប្រាំនាក់

ក៖ មានបងប្អូនប្រុសប្រាំនាក់ ចាស អូ....ត្រូវហើយទាំងអស់ប្រាំបីនាក់លោកពូណោះ!

ខ៖ ស្រីបីនាក់ប្រុសប្រាំនាក់ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ហើយអញ្ចឹងសព្វថ្ងៃនិងលោកពូមានទីលំនៅ នៅឯណាដែរលោកពូ?

ខ៖ អឺ....នៅផ្ទះហើយប្រពន្ធរបស់ខ្ញុំនៅកំពង់ចាម!

ក៖ អ៎....

ខ៖ ប៉ុន្តែអឺ....ខ្ញុំមកជួលផ្ទះនៅភ្នំពេញនេះតើ ជួលនៅពីរនាក់ប្រពន្ធនិង!

ក៖ អញ្ចឹងស្រុកកំណើតរបស់លោកពូនៅកំពង់ចាមទេហ៎?

ខ៖ ស្រុកកំណើតរបស់ខ្ញុំនៅខេត្តតាកែវ!

ក៖ លោកពូននៅខេត្តតាកែវវិញ?

ខ៖ ស្រុកកំណើតរបស់ខ្ញុំនៅអឺ....កំពុងចាមស្រុកកំណើតរបស់ប្រពន្ធនិងហ៎!

ក៖ អ៎....ចាស ហើយលោកពូរៀបការនៅក្នុងថ្ងៃ ខែ ឆ្នាំណាដែរ?

ខ៖ ការប្រហែលជាឆ្នាំ២០១៤!

ក៖ អូ....ហើយ....

ខ៖ ទើបរៀបការដែរនិង!

ក៖
ហើយចុះកាលនិងលោកពូរៀបការនិងដោយឪពុកម្តាយជាអ្នករៀបចំទុកដាក់អោយឬដោយស្រលាញ់គ្នាស្ម័គចិត្ត?

ខ៖ រៀបការដោយស្រលាញ់គ្នាស្គាល់គ្នាទៅស្រលាញ់គ្នានៅជាមួយគ្នាការតែម្តងទៅ!

ក៖ ចាស! ហើយសព្វថ្ងៃលោកពូមានក្រុមគ្រួសារលោកពូ មានកូនប៉ុន្មាននាក់ហើយ?

ខ៖ និយាយរួមទៅខ្ញុំមានកូនពីនាក់ហើយ!

ក៖ កូនរបស់លោកពូមានស្រីប៉ុន្មននាក់ហើយប្រុសប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូនស្រីម្នាក់ហើយកូនប្រុសម្នាក់!

កៈ អូ....ល្អមែនទែនចេះឆ្លាស់គ្នាល្អ (សើច) ហើយកូនស្រីនិងកូនប្រុសរបស់លោកពូមានឈ្មោះអ្វីដែរ? (មានសំលេងរំខានពីខាងក្រៅ)

ខៈ កូនប្រុសមានឈ្មោះអឺ....និយាយរួមទៅរឿងនិងវាពិបាកៗនិយាយប្រាប់ពីព្រោះថាពេលដែរខ្ញុំបានស្រលាញ់ប្រពន្ធរបស់ខ្ញុំនិងពោះម៉ាយកូនមួយហើយនិង ប្រពន្ធរបស់ខ្ញុំនិងមេម៉ាយកូនមួយហើយនិង ហើយទើបបានរៀបការជាមួយខ្ញុំនិងទើបបានកូនប្រុសមួយទៀត កូនរបស់ខ្ញុំដាក់នាមត្រកូលរបស់ខ្ញុំតែម្តង និយាយទៅដឹងតែឈ្មោះរបស់កូនខ្ញុំនិង ហើយកូនរបស់ខ្ញុំម្នាក់ទៀតដូចជាឈ្មោះភ្លេចបាត់ហើយខ្ញុំមើលនៅក្នុងសៀវភៅគ្រួសារបានឃើញ

កៈ ចាស! ហើយសព្វថ្ងៃនិងលោកពូមានអឺ....អាយុប៉ុន្មានឆ្នាំហើយ? (មានសំលេងរំខានពីខាងក្រៅ)

ខៈ ខ្ញុំមានអាយុ៣៥,៣៦ឆ្នាំហើយ!

កៈ ចាស! លោកពូកើតនៅក្នុងថ្ងៃ ខែ ឆ្នាំ ណាដែរ?

ខៈ ខ្ញុំកើតអឺ....ឆ្នាំ៨៣ (ឆ្នាំ១៩៨៣) (មានសំលេងរំខានពីខាងក្រៅ)!

កៈ ថ្ងៃ ខែ ឆ្នាំ លោកពូអត់មានចាំទេហ៎?

ខៈ ខ្ញុំកើតនៅថ្ងៃទី១២ ខែ ០៧!

កៈ ថ្ងៃ ខែ ឆ្នាំ លោកពូត្រូវដូចនៅក្នុងអត្តសញ្ញាណប័ណ្ណទេលោកពូ?

ខៈ បាទ! ត្រូវតើ!

កៈ លោកពូមានយកអត្តសញ្ញាណប័ណ្ណមកឬអត់?

ខៈ អត់ៗបានយកមកផង!

កៈ ចាស! ហើយអឺ....ដូចជាលោកពូហើយអឺ....លោកពូមានក្រុមគ្រួសារនិងហើយបានរៀបការនៅក្នុងក្រុងភ្នំពេញឬបានរៀបការនៅស្រុកកំណើតខាងប្រពន្ធនៅកំពង់ចាម?

ខ៖ ខ្ញុំទៅរៀបការនៅខាងប្រពន្ធ!

ក៖ រៀបការនៅខាងកំពង់ចាមឯណោះលោកពូណោះ?

ខ៖ រៀបការនៅខាងកំពង់ចាម! (មានសំលេងរំខានពីខាងក្រៅ)

ក៖ អញ្ចឹងលោកពូរៀបការពីរដងហើយ រៀបការលោកទីមួយក្នុងឆ្នាំណាហើយរៀបការលោកទីពីនៅក្នុងឆ្នាំណាដែរ?

ខ៖ អំ....ខ្ញុំទើបតែរៀបការឆ្នាំទីមួយនិងគឺៗទើបរៀបការមួយប្រពន្ធមួយនិង!

ក៖ ចុះរៀបការជាមួយប្រពន្ធមុន?

ខ៖ អត់មានប្រពន្ធមុនមកពីណា ពីព្រោះប្រពន្ធរបស់ខ្ញុំគាត់មេម៉ាយកូនមួយ!

ក៖ អូ....សុំទោសលោកអំបាញ់មិញខ្ញុំស្តាប់ច្រឡំ (សើច)!

ខ៖ មិនមែនខ្ញុំពោះម៉ាយកូនមួយទេ គឺប្រពន្ធរបស់ខ្ញុំនិងគាត់មានកូនមួយមុនខ្ញុំហើយ អញ្ចឹងខ្ញុំអត់ទាន់មានប្រពន្ធអត់ទាន់មានកូនទេ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ ចាស! ចាស! អរគុណលោកពូដែលបានបញ្ជាក់សារជាថ្មីកុំអីច្រឡំបាត់(សើច) ហើយអឺម....ទាក់ទងជាមួយនិងអឺ....ទាក់ទងជាមួយនិងក្រុមគ្រួសាររបស់លោកពូមួយទៀតដូចជាខាងបងស្រីគាត់ធ្វើការអីដែរ?

ខ៖ និយាយទៅគាត់ធ្វើការនៅ Naga World គាត់ធ្វើខាងជាអ្នកចែកបៀរ!

ក៖ អំ....ចុះលោកពូៗមានការងារជាអ្វីដែរសព្វថ្ងៃ?

ខ៖ អឺ....ខ្ញុំបើកឡានដឹងភ្ញៀវ!

ក៖ លោកពូធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

ខ៖ ខ្ញុំចូរម៉ោងប្រាំពីរ ហើយចប់មិនដឹងម៉ោងប៉ុន្មានស្រេចតែភ្ញៀវដែរ!

ក៖ អូ....ចាស ហើយអឺ....អញ្ចឹងអឺ....លោកពូអាចគិតថានិងបានប្រាក់ចំណូលប៉ុន្មានសំរាប់ចិញ្ចឹមជីវិតរបស់លោកពូ ហើយលោកពូគិតថាវានិងអាចគ្រប់គ្រាន់ដែរឬទេ?

ខ៖

គឺប្រាក់ខែ....បើប្រាក់ខែខ្ញុំបានតិចដែរនិងវាជួនកាលប្រសិនបើយើងថែមម៉ោងថែមអីនិងវាបានដែរបានច្រើនទៅណាស់

បើតែប្រាក់ខែចាយមិនចង់គ្រាន់ទេពីព្រោះយើងជួលផ្ទះគេផងអីផងហើយយើងមករស់នៅភ្នំពេញអ្វីៗក៏វាថ្លៃបើប្រាក់ខែយើងតិចក៏វាពិបាកដែរ!

ក៖ ចាស! អឺ....អាចដូចជាក្នុងមួយខែលោកពូអាចរកបានប្រាំរយដុល្លាអីដែរទេលោកពូ? មានទេមានខែខ្លះអាចរកបានប៉ុណ្ណឹងទេ?

ខ៖ អត់ដល់នឹងទេប្រហែលបួនរយជាងអីនិងមាន!

ក៖

ពេលខែបុណ្យទានអីនិងមានមនុស្សច្រើនអញ្ចឹងលោកពូអាចរកបានច្រើនហើយលោកពូនេះ!

ខ៖ បាទ!

ក៖ ហើយឡានរបស់លោកពូរត់ពីខាងណាទៅខាងណាដែរ?

ខ៖ ខ្ញុំដឹកភ្ញៀវតែម្តុំភ្នំពេញនិង ជួនកាលប្រសិនបើភ្ញៀវទៅខេត្តយើងដឹកគាត់ទៅខេត្តប៉ុន្តែអត់មានទេភាគច្រើនដឹកនៅតែភ្នំពេញដាក់គេដល់ក្នុង Office ហើយចប់អត់ទំនេរគេណាត់ទៅគេតេហៅ បើគេអោយយើងនៅចាំគេយើងចាំទៅ!

ក៖ ចាស! ត្រូវហើយលោកពូ ហើយអឺ....ភ្ញៀវបរទេសភាគច្រើនមានគាត់មកជិះទេលោកពូ? ភ្ញៀវជនជាតិហាស? (មានសំលេងរំខានពីខាងក្រៅ)

ខ៖ និងហើយភ្ញៀវដែលខ្ញុំដឹកនិងភាគច្រើនដឹកសុទ្ធតែភ្ញៀវជនជាតិតើ ជួនកាលដឹកជនជាតិជប៉ុនជួនកាលដឹកភ្ញៀវចិនជួនកាលដឹកភ្ញៀវថៃអីនិងទៅ!

ក៖

ភាគច្រើនភ្ញៀវជនជាតិគាត់អឺ....ជិះឡានលោកពូពីណាទៅណាដែរគាត់ជិះទៅតាមតំបន់ទេសចរណ៍ឬក៏គាត់ជិះទៅកន្លែងធ្វើការរបស់ពួកគាត់?

ខ៖ ភ្ញៀវភាគច្រើនគាត់ទៅកន្លែងធ្វើការរបស់គាត់ដែរ!

ក៖ ភាគច្រើនជាភ្ញៀវជនជាតិចិនណោះលោកពូណោះ!

ខ៖ បាទ....?

កៈ ភាគច្រើនភ្ញៀវដែរលោកពូអឺ....ដឹកភាគច្រើនជាភ្ញៀវជនជាតិចិនត្រូវទេលោកពូ?

ខៈ ភាគច្រើនខ្ញុំដឹកភ្ញៀវជនជាតិជប៉ុនច្រើនជាងគេ!

កៈ ភ្ញៀវជនជាតិជប៉ុនច្រើនជាងគេវិញ? អញ្ចឹងកន្លែងធ្វើការរបស់ពួកគាត់ភាគច្រើននៅម្តុំណាវិញលោកពូនៅម្តុំកោះពេជ្របូក៏កន្លែងណាផ្សេង?

ខៈ នេះនៅជិតនេះទេ Office នៅកន្លែងធ្វើការរបស់គាត់នៅជិតៗនេះទេ!

កៈ នៅជិត....?

ខៈ អានឹងយើងអត់និយាយអោយប៉ះពាល់ទៅដល់កន្លែងក្រុមហ៊ុនគេទេ!

កៈ អូ....ចាស ហើយឡាននិងជាឡានរបស់គេទេអញ្ចឹងលោកពូមិនមែនធ្វើការអឺ....បើកឡាននិងនៅខាងក្រុមហ៊ុនទេហ៎ លោកពូបើកឡាននិងជារបស់លោកពូផ្ទាល់ហើយលោកពូធ្វើការរត់និងដោយខ្លួនឯង?

ខៈ ឡាននិងក៏ជាឡានរបស់គេដែលនិងខ្ញុំស៊ីប្រាក់ខែគេនិងទេ!

កៈ ចាស!

ខៈ មិនមែនឡានរបស់ខ្ញុំឯណារបស់គេបានប្រាក់ខែតែបន្តិចបន្តួចនិងចង់រកកន្លែងណាមានអូធី (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាស! ហើយលោកពូចង់បានប្រាក់ខែចំនួនប៉ុន្មានដែរ?

ខៈ ប្រាក់ខែយើងប្រសិនបើជាបានត្រឹមតែ....ប្រាក់ខែគោលបានត្រឹមតែពីររយហាសិបដុល្លាឡើងទៅក៏ល្អដែរ បើបានត្រឹមពីរយក្រោមពីររយដុល្លាអីនិងក៏វាពិបាកដែរបានត្រឹមតែមួយស៊ីមួយចាយក៏មិនសល់ដែល!

កៈ ចាស! ត្រូវហើយ! (មានសំលេងរំខានេពីខាងក្រៅ)

ខ៖ ហើយប្រសិនបើបានត្រឹមតែពីររយហាសិបដុល្លានិងប្រយ័ត្នតែយើងរកក្រៅមិនសូវបាននិងក៏វាគ្មានសល់ដែលបានត្រឹមតែចាយប្រចាំថ្ងៃនិងអស់ដដែលៗនិង!

ក៖ ចាស!

ខ៖ ប្រសិនបើយើងបានត្រឹមខ្ទង់បួនរយដុល្លាជាងនិងទើបបានសល់តិចតួចដែរ!

ក៖ ចាស! ហើយលោកពូមានការងារក្រៅពីនិងឬទេ? (មានសំលេងរំខានពីខាងក្រៅ)

ខ៖ ខ្ញុំអត់មានធ្វើការងារក្រៅទេមានតែការងារមួយនិង!

ក៖ អញ្ចឹងលោកពូមានតែការងារនិងមួយទេ ហើយចុះលោកពូមានចង់ធ្វើការងារអ្វីបន្ថែមក្រៅពីនិងដែរឬទេ?

ខ៖ ចេះតែចង់ធ្វើហើយតែមិនដឹងធ្វើការងារអ្វីផងរកនឹកមិនឃើញ (សើច)!

ក៖ (សើច) នៅអត់ទាន់មានគំរោងការធ្វើអ្វីផ្សេងទេណ៎លោកពូណ៎? ហើយសំរាប់អឺ....កាលពីមុនលោកពូបានសិក្សារនៅឯណាដែរលោកពូ?

ខ៖ ខ្ញុំបានឈប់រៀនយូរដែរហើយនិង ឈប់តាំងពីឆ្នាំកៅជាង (ឆ្នាំ១៩៩០ជាង) !

ក៖ លោកពូឈប់តាំងពីឆ្នាំ១៩៩០ជាងតាំងពីដាច់សម័យប៉ុលពតម៉ងទេដឹង? ដាច់ពីសម័យប៉ុពតឆ្នាំចិតសិបប្រាំបួន(ឆ្នាំ១៩៧៩) ហើយកាលនិងលោកពូអឺ....!

ខ៖ នៅខ្ទង់នេះនៅខ្ទង់ជិតឆ្នាំពីពាន់ហើយ ប្រហែលឆ្នាំ១៩៩៩!

ក៖ នៅក្នុងឆ្នាំ១៩៩៩លោកពូបានឈប់រៀន!

ខ៖ នៅក្នុងឆ្នាំ១៩៩៩និងដូចជាចង់ភ្លេចហើយនៀក! (មានសំលេងរំខានពីខាងក្រៅ)

ក៖ លោកពូបានរៀននៅក្នុងសាលាណាដែលលោកពូ?

ខ៖ ខ្ញុំរៀនសាលាមានច្រើនណាស់ពីព្រោះខ្ញុំរៀនបានផ្ទេរសាលាតែរហូតនិងតាំងពីរៀននៅតាកែវផ្ទេរទៅរៀននៅភ្នំពេញ
ភ្នំពីពេញផ្ទេរទៅរៀននៅកំពង់សោមឈប់រៀនត្រឹមកំពង់សោមនិង!

ក៖ លោកពូបានឈប់រៀនត្រឹមថ្នាក់ទីប៉ុន្មានដែរលោកពូ?

ខ៖ ខ្ញុំបានរៀនត្រឹមអនុវិទ្យាល័យនិងក៏ឈប់រៀនទៅ!

ក៖ អនុវិទ្យាល័យអញ្ចឹងឈប់រៀនត្រឹមថ្នាក់ទីប្រាំបួន!

ខ៖ អត់ដល់និងទេខ្ញុំទើបនិងរៀបចូលៗអនុវិទ្យាល័យនិងខ្ញុំឈប់ហើយ!

ក៖ អ៎....

ខ៖ ដល់អនុវិទ្យាល័យនិងខ្ញុំឈប់រៀន រៀនបានតែបន្តិចនិង!

ក៖ ចុះលោកពូចេះបានប៉ុន្មានភាសារដែរ?

ខ៖ អឹម....តែភាសាខ្មែរខ្ញុំចេះមិនចង់សព្វផង!

ក៖ (សើច) អញ្ចឹងមានន័យថាលោកពូចេះតែមួយភាសាទេណោះលោកពូណ៎!

ខ៖ និងហើយចេះតែមួយភាសានិងទេ!

ក៖ ចាស! ហើយអឹម....លោកពូកាលពីក្មេងលោកពូមានស្រមៃចង់ធ្វើអ្វីទេពេលធំឡើង?

ខ៖ ខ្ញុំអត់ដែលស្រមៃអីផងគ្រាន់តែថាចង់ធ្វើអឺ....ជា....ចង់ធ្វើខាងអេឡិចត្រូនិចនិងមេកានិចវិញចង់ចេះខាងនិងព្រោះពីមុននិងខ្ញុំដើរតែរៀនដល់ពេលអញ្ចឹងទៅមិនដឹងចាប់យកមួយណាដល់ពេលចុះឡើងៗអត់មានចាប់បានអីមួយ!

ក៖ ចាស! មេកានិចខាងរបៀបខាងជួសជុលអីនិងណ៎លោកពូ!

ខ៖ បាទ! ពីមុនមកខ្ញុំរៀនខាងជាងឡានបានតែបន្តិចក៏ឈប់ហើយខ្ញុំរៀនជាជាងម៉ាញ៉េ(វិទ្យុ)បានចេះបានគួរសមដែរឈប់ទៀតហើយបានទៅរៀនខាងជាងទូរស័ព្ទទៀត រៀនបានចេះតែន្តិចឈប់ទៀត (សើច) រៀនដូចអត់ប្រាកដដែរពីព្រោះពិបាកលុយរៀនដែលឈប់តែម្តងទៅខ្វះលុយរៀនដែរឈប់តែម្តង មកធ្វើការដល់សព្វថ្ងៃនិង!

ក៖ ចុះលោកពូមុននិងមកបើកឡាននិង លោកពូធ្លាប់ជួសជុលទូរស័ព្ទដែរអញ្ចឹង!

ខ៖ អឺ....មុនខ្ញុំមកបើកឡាននិងខ្ញុំធ្លាប់ធ្វើខាងជុះជុលទូរស័ព្ទ!

ក៖ លោកពូធ្លាប់ជួសជុលទូរស័ព្ទហើយនិងជាងម៉ាញ៉េហើយនិងជួសជុលឡានដែរ!

ខ៖ បាទ! ខ្ញុំជួសជុលឡានដែរ!

កៈ ចុះលោកពូមានធ្វើការងារអ្វីផ្សេងទៀតទេ?

ខៈ ការងារផ្សេងរបស់ខ្ញុំបើនិយាយរួមទៅតាំងពីមុនឆ្នាំ២០០៩មកអេ....ឆ្នាំ២០០៩ខ្ញុំធ្លាប់ទៅៗនេសាទត្រីនៅក្រៅប្រទេស!

កៈ នេសាទត្រីនៅក្រៅប្រទេសហ៎លោកពូ? ហើយទៅនេសាទនៅប្រទេសណាដែរ?

ខៈ ខ្ញុំទៅតាមខ្សែររយៈ ទៅតាមទៅតាមក្រុមហ៊ុនចិននិង ក្រុមហ៊ុនចិនទៅអីគេទៅនេសាទនៅប្រទេសអូស្រ្តាលី កាលនិងខ្ញុំទៅនេសាទទៅតាមក្រុមហ៊ុនចិននិង!

កៈ អូ....ហើយលោកពូទៅបានប៉ុន្មានឆ្នាំដែរ? (មានសំលេងរំខានពីខាងក្រៅ)

ខៈ ខ្ញុំទៅបានមួយឆ្នាំមួយខែ!

កៈ ទៅបានយូរដែរហើយណោះលោកពូណ៎ អញ្ចឹងបទពិសោធន៍ការងារនៅទីនោះបានច្រើនដែរហើយយ៉ាង? គេប្រើអោយលោកពូធ្វើអ្វីខ្លះនៅនិង?

ខៈ បើយើងទៅដំបូងអត់សូវចេះអញ្ចឹងគេប្រើអោយធ្វើអីក៏ធ្វើនិងទៅ!

កៈ គេប្រើអោយលីត្រីសែងត្រីរកត្រីអញ្ចឹងទៅណ៎លោកពូ?

ខៈ និងគេអោយយើងមើលខ្សែរចងខ្សែរទៅ ហើយនិងមើលខ្សែរលើទូកទៅ (មានសំលេងរំខានពីខាងក្រៅ)!

កៈ ហើយគេអោយប្រាក់ខែលោកពូក្នុងមួយខែបានប៉ុន្មានដែរលោកពូ?

ខៈ និងប្រសិនបើយើងទៅតាមក្រុមហ៊ុនចិន ពីព្រោះកាលនិងគេអោយប្រាក់ខែរាងតិចដែរនិង ក្នុងមួយខែគេអោយមួយរយហាសិបដុល្លា (១៥០$) !

កៈ គេអោយតែ១៥០ដុល្លាទេ? បានតិចម្លេះលោកពូនៅអូស្រ្តាលីយើងញាំមិចគ្រាន់ស៊ីចាយអីលើគេដែលមែន?

ខៈ អានិងយើងមិនមែនបានប្រាក់ខែពីអូស្រ្តាលីទេ ពីព្រោះក្រុមហ៊ុនចិននិងបើពេលនិងយើងគ្រាន់តែទៅៗ កាលនិងយើងអត់ដឹងហ៎

បើលើសពីរបីខែឡើងទៅគេតំឡើងប្រាក់ខែអោយយើងច្រើនជាងនិងទៀតណាស់ ប៉ុន្តែយើងខ្មែរដល់យូរៗទៅគេស៊ីពីលើយើងឡើងពាក់កណ្តាលទំរាំតែយើងដឹងដល់ពេលដឹងមកវិញមកខ្ជិលនៅ!

ក៖ អូ....

ខ៖ ទៅបានមួយឆ្នាំមកវិញសល់មិនបានដល់ពីរពាន់ដុល្លាផងហួសចិត្ត (សើច)!

ក៖ ចុះបានតែមួយរយដុល្លាជាងនិងលោកពូ ហើយលោកពូទៅដែលបានប្រាក់ខែតែបន្តិចនិងពីព្រោះអីចាយលើគេហ៎ បានលោកពូទៅដេកអីនិងគេអោយយើងចេញទេ?

ខ៖ អើយ....និងយើងស៊ីនៅលើគេទាំងអស់ពីព្រោះអីលុយយើងអត់មានបានត្រូវចាយអីផងនិងចាយតែពេលយើងចូលមកកាប៉ាល់មកដល់ច្រាំងអីនិងទៅ អានិងវា....យើងចាយបានតែមួយភ្លែតៗ តែចាយបួនរយដុល្លាអីនិងបានតែមួយភ្លែតនិងនៅស្រុកគេ! (មានសំលេងរំខានពីខាងក្រៅ)

ក៖ និងហើយថ្លៃៗណាស់លោកពូ អញ្ជឹងបទពិសោធន៍របស់លោកពូមួយឆ្នាំកន្លះនិងលោកពូចងចាំអីគេខ្លះកាលនិង?

ខ៖ ចងចាំត្រង់ថាទៅស្ទូចត្រីខ្ញុំទៅស្ទូចត្រីអាត្រីអីគេ....ត្រីធូណាហ៎!

ក៖ ចាស!

ខ៖ កាលនិងយើង ប្រសិនបើខាងយើងធ្វើដូចគេបាន ប៉ុន្តែត្រង់ថាសមុទ្ររបស់យើងអត់មានត្រីនិង មកពីត្រីនិងធ្វើអោយខ្ញុំមានបទពិសោធន៍ជាងគេ ប្រសិនបើខ្ញុំមានប្រព័ន្ធចាប់ GPS ដូចគេខ្ញុំចាប់បានប្រសិនបើសមុទ្រយើងមានត្រីនិងត្រីធូណានិងដូចគេខ្ញុំអាចនេសាទនិងចាប់ត្រីនិងបានដែរ ពីព្រោះវាស្រួលបិទនុយវាស៊ីនុយនិងទៅយើងអាចនេសាទបានហើយ!

ក៖ អ៎....អញ្ជឹងក្នុងមួយថ្ងៃអាចស្ទូចត្រីនិងបានប៉ុន្មានគីឡូដែរលោកពូ?

ខ៖ ច្រើនដែររាប់តោនដែរនិង!

ក៖ លោកពូស្ទូចឬក៏បោះៗមង?

ខ៖ ត្រីនិងគេស្ទួចនិយាយទៅគេដាក់បន្តែតចោលបីម៉ោងអីនិងគេសារស្ទួចឡើងវិញទៅត្រីគេធំៗកាលនិងគេបន្តែតចោលៗហើយនិងគេប្រលែងចោលកណ្តាលសមុទ្រតែម្តងដល់ពេលGPS
របស់គេដូចថាគេដាក់អង់ទែនមួយមកដាក់បង្គោលដូចទង់និងណាស់គេប្រលែងបោះចោលទៅហើយគេមើលតែអាពដារបស់គេនិងហើយជិះទៅយកវិញទៅស្រាល(សារ)ទៅត្រីជាប់នៅនិងទៅជាប់និងសន្ទូចដែលគេវាយចោល!

ក៖ ត្រីនិងប្រហែលជាបីគីឡូទៅប្អូនគីឡូអីនិង (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បើបីប្អូនគីឡូគេអត់យកទេត្រីនិងគេយកចាប់ពីប្រាំបីគីឡូឡើងទៅបានគេយក!

ក៖ អញ្ចឹងទៀតតែត្រីធូណានិងតូចៗនិង!

ខ៖ តូចៗនៅនេះត្រីសមុទ្រនៅនេះតូចៗ តែបើត្រីនៅសមុទ្រប៉ាស៊ីហ្វិចធំៗ

ក៖ (សើច)

ខ៖ ប្រាំពីគីឡូអីនិងគេអត់យកទេអឺ....ត្រឹមប្រាំគីឡូអីនិងគេបោះចោលហើយ!

ក៖ ចាស!

ខ៖ តតែអត់ត្រីបានគេយកត្រឹមប្រាំពីរគីឡូអីនិងហ៎!

ក៖ ចាស! អូ....ត្រីធំណាស់ធំជាងខ្លួនទៀតមើលទៅ!

ខ៖ ត្រីនិងធំជាងខ្លួនផង! (មានសំលេងរំខានពីខាងក្រៅ)

ក៖ (សើច) ហើយចុះកាលនិងគេយកត្រីនិងលក់ចេញទៅណាដែលលោកពូ?

ខ៖ និងជូនកាលគេមានកាប៉ាល់ចិនចឹងគេមកយកកាប៉ាល់ជប៉ុនអញ្ចឹងគេមកយកដល់ៗកន្លែងៗ!

ក៖ អឺម....

ខ៖ កាលខ្ញុំទៅនិងមួយឆ្នាំទើបបានឡើងច្រាំងម្តង!

ក៖ អូ....ឃើញថាមើលទៅសុទ្ធតែសមុទ្រ!

ខ៖ សុទ្ធតែសមុទ្រ ងូតតែទឹកសមុទ្រនិងឡើងចង់សោះខ្លួនហើយ!

កៈ (សើច) ហើយចុះទឹកអីធ្វើយ៉ាងមិចទៅពេលពេលលោកពូនេះ គេមានទឹកសាបដាក់ទៅទេ?

ខៈ ទឹកសាបនិងគេបំលែងពីទឹកប្រៃមកតើ!

កៈ អូ....ឡូយណាស់អញ្ចឹង!

ខៈ
ប៉ុន្តែវាមិនសូវនេះទេពេលដែរយើងទុកវាយូរទៅៗវារងជាតិប្រៃសវាប្រៃសឃើញប្រៃសឃើញអីចឹងពេលដែលយើងផឹកទៅវាអាចប៉ះពាល់ទៅដល់សុខភាពណាស់!

កៈ លោកពូមានដែលឈឺទេពេលនៅទីនោះ?

ខៈ ឈឺដែរតើ តែទៅមួយឆ្នាំឈឺយ៉ាងច្រើនពីរដងអីនិង ឈឺច្រើនពេកក៏គេស្តីអោយ!

កៈ ចាស! និយាយទៅលោកពូការងារច្រើនហើយបានបទពីសោធន៍ច្រើនទៀតអញ្ចឹងការងារក្នុងចំនោមទាំងអស់និងដូចជាលោកពូធ្លាប់ទៅនេសាទត្រីធ្វើជុះជុលឡានជុះជុលអី....គ្រឿងទូរស័ព្ទហើយអី....និងបើកឡាននិង
តើាការងារទាំងបីនិងលោកពូចូរចិត្តស្រលាញ់មួយណាជាងគេ?

ខៈ និយាយទៅកាលពីមុនបើយើងធ្វើការនេសាទត្រីនិងយើងចូរចិត្តដែរប៉ុន្តែនៅស្រុកខ្មែរយើងពិបាករកណាស់ត្រីហ៎ ពីព្រោះសមុទ្រវាតូចឥឡូវបើកឡាននេះឥឡូវនិងក៏ខ្ញុំរាងធុញដែរ ធុញរឿងអីគឺធុញរឿងផ្លូវស្ទះនិងតែម្តងតែឥឡូវនិងខ្ញុំខ្ជិល
ចង់លាឈប់ហើយពីព្រោះវាមិនយូរទេចង់ឈប់ពីបើកឡាននិងដែលហើយទៅរកធ្វើអីផ្សេង!

កៈ អឹម....ចាស ហើយអី....ការងារនិមួយៗ តើលោកពូបានឆ្លងកាត់អ្វីខ្លះ? អី....អី....បានធ្វើការនិង
តើលោកពូចងចាំការងារមួយណាដែលលំបាកជាងគេនៅក្នុងជីវិតរបស់លោកពូ
តើមានដែរឬទេលោកពូ?

កៈ បាយទឹកអីនិងលោកពូអាចពិសាបានរបបនិង លោកពូអាចញាំបានហើយនេះ!

ខៈ វាមិនមានអីទេពីព្រោះគេមានម្ហូបអីត្រឹមត្រូវគ្រាន់តែយើងនៅលើកាប៉ាល់និងវាលំបាកអី....រឿងដេកអីនិងយើងដេកបានតែបួនម៉ោងបីម៉ោងអីនិង

ហើយយ៉ាងយូរដេកបានតែប្រាំម៉ោងអីនិងងើបវិញហើយ ងើបធ្វើរហូតឈរតែរហូតនិង ហើយប្រាក់ខែតិចពេកដល់ពេលអញ្ចឹងខ្ជិលខ្ញុំឈប់តែម្តងទៅ!

ក៖ ចាស! ហើយគេមានដែរបានធ្វើបាបលោកពូទេ ដូចជាត្រូវគេវាយអីអញ្ចឹងណាស់?

ខ៖ មានដែរគ្រាន់ថាអឺ....ខ្ញុំទៅនិងវាងស្លូតជាងគេហើយបើក្រៅពីនិងគេវាយតែទាំងអស់និង!

ក៖ អឺ....(សើច)!

ខ៖ ពីព្រោះខ្ញុំ ពីព្រោះនៅលើកាប៉ាល់និងមានច្រើនមានគ្រប់ជាតិសាសន៍និងមានចិន ជប៉ុន ហ្វីលីពីន ឥណ្ឌូនេស៊ី ខ្មែរ យួន(វៀតណាម) មានប្រាំ ប្រាំមួយសាសន៍ឯណោះ!

ក៖ មានជនជាតិជប៉ុនដែរ?

ខ៖ ជនជាតិជប៉ុនមានដែរ តែជប៉ុនភាគច្រើនចិន យួន ហើយនិងជប៉ុន ហើយនិងហ្វីលីពីនវាអត់សូវនេះទេពីព្រោះវាធ្លាប់មានបទពីសោធន៍ណាស់ ដល់ពេលខ្មែរយើងទៅវាវាងអត់សូវមានបទពីសោធន៍វាវាងៗពិបាក!

ក៖ ចាស! ហើយអឺ....លោកពូអញ្ចឹងតាមរយះជីវិតរបស់លោកពូតាំងពីតូចមកដល់ឥឡូវនិងលោកពូចងចាំជីវិតអឺ....ដែលលោកពូធ្លាប់ជួបប្រទះ តើលោកពូមានពូចងចាំកន្លែងណាជឬលធ្វើអោយលោកពូចងចាំហើយគ្មានភ្លេចសោះឡើយដែលធ្វើអោយលោកពូពិបាកចិត្ត?

ខ៖ និយាយទៅធ្វើការនៅក្រៅក្នុងមួយឆ្នាំនិងហើយចាំរហូត (សើច)ពីព្រោះមួយឆ្នាំនិងខ្ញុំទៅធ្វើការនិងខ្ញុំនៅលើសមុទ្រខ្ញុំងូតទឹកសមុទ្រ បើនិយាយរួមទៅពិបាកជាងគេគឺអាពេលយើងទៅនិងតែម្តង យើងអត់ដឹងថាទៅៗសាទ្រនិង យើងស្មានតែវាស្រួលពីព្រោះគេប្រាប់ថាទៅបីខែបានវាមកច្រាំងម្តងខ្ញុំថាបើបីខែនិងក៏វាអត់អីដែរតែមិនមែនបីខែទេគឺមួយឆ្នាំបានចូរច្រាំងម្តងអញ្ចឹងធ្វើអោយយើងពិបាក!

ក៖ អូ....ចាស ហើយអាពេលដែលកាលនិងខុសអ្វីដែលយើងបានគិតនិងគេបានសន្យានិងយើងទើបបានជាលោកពូទៅ? (មានសម្លេងរំខានពីខាងក្រៅ)

ខ៖ គេនេះដែលគ្រាន់តែថាអើយ....ប្រសិនជាយើង ហើយគេកំណត់អោយយើងបីឆ្នាំប្រសិនបើយើងបីឆ្នាំនិងយើងធ្វើចប់កំណត់របស់គេបីឆ្នាំនិង យើងអើយ....កុងត្រាជាមួយគេបីឆ្នាំប្រសិនបើជាយើងមកវិញអញ្ជឹងបានលុយច្រើន វាអាចបានលុយច្រើនហើយសំបុត្រយន្តហោះក៏គេចេញអោយដែល!

ក៖ អឺម....

ខ៖ ប៉ុន្តែយើងខុសៗអឺ....សន្យាគេបីឆ្នាំនិងគឺមកវិញគឺអត់ទេគឺសំបុត្រយន្តហោះនិងយើងចេញខ្លួនឯង ពីព្រោះអីខ្ញុំធ្វើបានតែមួយឆ្នាំនិងមកវិញបានជិះយន្តហោះនិងវាអស់លុយនិងហើយវាកាត់អស់រលីង!

ក៖ អឺម....

ខ៖ វាគ្មានបានសល់លុយអីទេ ពីព្រោះខ្ញុំវាលំបាកពេកនៅលើកាប៉ាល់និង វាមិនស្រួលទេពីព្រោះវាមានសត្វអ្វីម៉្យាងនោះដូចសត្វតុកកែវាដូចសត្វតុកកែអញ្ជឹងវាខាំយក យើងកន្ទួលពេញនិងតែម្តង!

ក៖ អូ....

ខ៖ ហើយងូតតែទឹកសមុទ្រវាពិបាកណាស់!

ក៖ មានអាសត្វតុកកែនៅក្នុងទូកនិងតែម្តង វាមកពីណាមកវិញឬវាមកពីក្នុងសមុទ្រ?

ខ៖ អានិងមិនដឹងសត្វស្អីវាទេ!

ក៖ អាសត្វនិងវាមានស្លាបទេលោកពូ?

ខ៖ សត្វនិងវាអត់មានស្លាបទេវា វាដូចតុកកែគីងគើម ប៉ុន្តែវាតូចៗវាដូចចៃអញ្ជឹងរបៀបដូចអាមេចៃធំៗនិងហាស ប៉ុន្តែវាខាំពេលដេកមិនស្រួលអញ្ជឹងទៅវាខាំៗចុយម្រាយហើយ!

ក៖ អូ....

ខ៖ វាធ្វើអោយយើងនៅមិនសុខតែម្តងណាស់បានមកវិញ!

កៈ ចាស!

ខៈ
យើងដេកនៅនិងសមុទ្រនិងដឹងស្រាប់ហើយដេកនៅលើកប៉ាល់ទោះបីកាប៉ាល់និងធំមែនតែវាអឺ....!

កៈ វារាងឃ្លីងឃ្លោង?

ខៈ
និងហើយវារាងឃ្លីងឃ្លោងពេលដែលអឺ....មានភ្លៀងខ្លាំងអីនិងវានៅតែមានរលកធំៗអីនិងដដែលនិងអឺ....គឺយប់ណាក៏ដែកមិនលក់ដែរ!

កៈ បាប៉ាល់និងប្រហែលជាធំជាងផ្ទះនិងទេដឹងលោកពូ?

ខៈ អេ....វាប្រហែលជាធំជាងនិង! (មានសំលេងរំខានពីខាងក្រៅ)

កៈ កាប៉ាល់និងវាមានពីជាន់មែនលោកពូ?

ខៈ កប៉ាល់និងមានេពីរជាន់គឺ....ខាងក្រោមនិងគេទុកអោយកម្មករដេកហើយជាន់លើរបស់កាពីទែន
អឺ....មានគ្នាច្រើនដែរនៅក្នុងកាប៉ាល់និងប្រហែលជាមានគ្នាសាមសិបនាក់ជាង!

កៈ
អឺម....អញ្ចឹងហើយសម្រាប់បទពិសោធន៍ល្អៗនៅក្នុងជីវិតរបស់លោកពូវិញតាំងពីមុនរហូតមកដល់ឥឡូវនិង តើលោកពូមានការចងចាំអ្វីគេខ្លះនៅក្នុងជីវិតរបស់លោកពូ?

ខៈ បទពិសោធន៍ល្អៗគឺអឺ....ការធ្វើជាជាងផ្ទះពីព្រោះខ្ញុំធ្លាប់ធ្វើកាលពេលដែរខ្ញុំឈប់រៀននិងខ្ញុំទៅធ្វើផ្ទះឪពុករបស់ខ្ញុំធ្វើជាជាងឈើនិងធ្វើផ្ទះល្មមៗកាលនិងខ្ញុំធ្វើតែផ្ទះឈើទេគឺធ្វើផ្ទះល្មមៗនិង
បើត្រឹមនៅខ្លួនឯងខ្ញុំអាចធ្វើបានវាស្រួលធ្វើណាស់ ជាងឈើមិនមែនជាជាងសំណង់ទេណាស់ពីព្រោះកាលដែលខ្ញុំឈប់រៀននិងធ្វើតែជាងឈើអីនិងទេដល់ជាងសំណង់មិនសូវធ្វើទេភាគច្រើនធ្វើជាជាងសំណង់ច្រើនជាង
អានិងៗពេលដែលខ្ញុំឈប់ពីរៀនមកគឺខ្ញុំចាប់ផ្ដើមដើរទៅជួយធ្វើផ្ទះកាលនិងរកបាន
និងហើយជាការងារដំបូងរបស់ខ្ញុំហើយនិងណាស់ បន្ទាប់មកបានទៅរៀនធ្វើអីផ្សេងៗទៀតបើការងារដំបូងនិងគឺជាងផ្ទះជាងឈើនិងហើយ (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាស! លោកពូមានអីទៀតទេទេលោកពូ?

ខ៖ អតើមានអីទៀតទេ!

ក៖ ចាស! អញ្ចឹងជាចុងក្រោយលោកពូមានពាក្យពេច៍អ្វីចង់ផ្ដាំផ្ញើរដល់អ្នកដែលបានស្ដាប់ជាពិសេសកូនចៅរបស់លោកពូជំនាន់ក្រោយទៀតណាស់!

ខ៖ គ្រាន់តែថាអោយកូនចៅជំនាន់ក្រោយនិងអោយបានរៀនសូត្រអោយបានចេះដឹងកុំអោយដូចខ្ញុំអញ្ចឹងរៀនចាប់យកអីៗក៏អត់បានខ្ញុំរៀនចំណោះច្រើនពេកក៏ប៉ុន្ដែអត់ចេះគ្មានអីទេមានតែអោយខំប្រឹងរៀនទៅកុំអោយយើងល្ងង់ ពីព្រោះពិបាករកការងារធ្វើសម័យនេះហើយ ពីព្រោះសម័យនេះគេត្រូវការចេះភាសាបើយើងអត់ចេះអក្សរនិងវាយើងនៅតែធ្វើកម្មករគេអញ្ចឹងណាស់ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាស! លោកពូហើយអញ្ចឹងលោកពីមានអ្វីបន្ថែមទៀតទេលោកពូតើមានអ្វីបន្ថែមទៀតទេ?

ខ៖ អោយបន្ថែមដូចជាគ្មានអ្វីបន្ថែមទៀតទេគ្រានើតែថាកូនខ្ញុំមិនចង់អោយកូនខ្ញុំដើរទៅនេះទៅនោះ ពីព្រោះអីរឿងផឹកស៊ីក៏មិនចង់អោយកូនខ្ញុំចេះដែរ ពីព្រោះខ្ញុំមានកូនប្រុសមួយអញ្ចឹងខ្ញុំចេះតែបារម្ភណ៍ហើយកុំអោយដូចខ្ញុំអីអញ្ចឹងអនាគត់ល្អមិនល្អមិនចង់អោយវាដើរពីព្រោះក្មេងៗនេះដែរនិង (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាស! លោកពូអស់ត្រឹមប៉ុណ្ណឹងហើយលោកពូ?

ខ៖ បាទ!

ក៖ ចាស! អរគុណច្រើនលោកពូសំរាប់ថ្ងៃនេះដែរបានចំណាយពេលអោយខ្ញុំបានសំភាសន៍!